00644898

E50

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 02 / 2011
ម៉ោង (Time/Heure): 14:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007/ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

**សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ**

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4 ,Chaom Chau, Dangkao, Phnom Penh, Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

00644899

ស ស្វាន

Jacques VERGÈS

Philippe GRECIANO

## ១. សេចក្តីផ្តើម

១. នួន ជា និង ខៀវ សំផន បានដាក់សំណើសុំដោះលែងឱ្យមានសេរីភាព នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ ហើយ អៀង ធីរិទ្ធ បានដាក់សំណើសុំដោះលែងឱ្យមានសេរីភាព នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១[១]។ សំណើសុំបានចោទប្រកាន់លើបញ្ហាជាច្រើន ហើយក្នុងចំណោមការចោទប្រកាន់ទាំងនោះ មានការចោទប្រកាន់មួយថា ដោយសារសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ពុំមានសំអាងហេតុ សាលដីកានេះធ្វើឱ្យសេចក្តីសម្រេចនានានៃការឃុំខ្លួនជនជាប់ចោទមិនមានសុពលភាពនោះទេ។ ដូចនេះ ជនជាប់ចោទត្រូវតែបានដោះលែងឱ្យមានសេរីភាពភ្លាម[២]។

## ២. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញដីកាដំណោះស្រាយលើសំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក ("សំណុំរឿងលេខ ០០២") និងបានបង្គាប់ឱ្យបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទទាំងបួនរូប រហូតដល់ជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[៣]។ អង្គបុរេ-

---

[១] "សំណើសុំដោះលែង នួន ជា បន្ទាន់" ឯកសារលេខ E19 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១។ "សំណើសុំដោះលែងឱ្យមានសេរីភាព យោងតាមវិធាន ៨២(៣) នៃវិធានផ្ទៃក្នុង" ឯកសារលេខ E18 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១។ "សំណើបន្ទាន់ដើម្បីឱ្យដោះលែងអ្នកស្រី អៀង ធីរិទ្ធ ដោយឥតបង្អង់" ឯកសារលេខ E21 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

[២] "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារលេខ D427/4/14 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ")។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារលេខ D427/1/26 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ")។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារលេខ D427/3/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ")។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ" ឯកសារលេខ D427/5/9 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី")។

[៣] ដីកាដំណោះស្រាយ ឯកសារលេខ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ "ជំពូក ទី៦៖ ការរក្សាការឃុំខ្លួនបណ្តោះអាសន្ន"។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

ជំនុំជម្រះ (“អ.ប.ជ”) បានទទួលសំណុំរឿង បន្ទាប់ពីមេធាវីការពារក្តីទាំងបួនក្រុមបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[៤]។ គ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោមជនជាប់ចោទទាំងបីនាក់ដែលបានដាក់សំណើសុំនេះ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នដែលមានចែងក្នុងដីកាដំណោះស្រាយទៅ អ.ប.ជ នោះទេ[៥]។

៣. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកា ដោយមិនមានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយ (“សាលដីកាលើដីកាដំណោះស្រាយ”) បន្ថែមទៅលើសាលដីកាលើបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែករបស់ អៀង សារី លើការឃុំខ្លួនបណ្តោះអាសន្ន ដោយអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា សេចក្តីសម្រេចមានសំអាងហេតុនឹងត្រូវចេញនាពេលខាងមុខ[៦]។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ទាំងនេះបានបង្គាប់ឲ្យបន្តការឃុំខ្លួនជនជាប់ចោទទាំងបួនរូបជាបណ្តោះអាសន្នបន្តទៀត រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៤. នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុរបស់ខ្លួន ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកលើការឃុំខ្លួន អៀង សារី ព្រមទាំងសំអាងហេតុសម្រាប់ផ្នែកឃុំខ្លួន នួន ជា និង អៀង ធីរិទ្ធ[៧] ដូចដែលបានបង្គាប់នៅក្នុងសាលដីកាលើបណ្តឹង

[៤] “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ” ឯកសារលេខ D427/3/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។ “បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ” ឯកសារលេខ D427/2/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។ “បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ” ឯកសារលេខ D427/1/6 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០។ “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ” ឯកសារលេខ D427/4/3 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។

[៥] ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តី អៀង សារី ពិតជាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួន។ *សូមមើល* “បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ” ឯកសារលេខ D427/5/1 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០។

[៦] “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៣”។ “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ” ទំព័រ៤-៥។ “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ” ទំព័រ៦-៧។ “សាលដីកាលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី” ទំព័រ៣-៤។

[៧] “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ” ឯកសារលេខ D427/5/10 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។ “សាលដីកាលើបណ្តឹងឧទ្ធរណ៍

00644902



ឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ នៅថ្ងៃដដែលនោះដែរ អ.ប.ជ ក៏បានចេញសំអាងហេតុរបស់ខ្លួនចំពោះសាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងករណី ខៀវ សំផន[៨]។ នៅថ្ងៃទី ២៤ ខែ មករា អ.ប.ជ បានចេញសំអាងហេតុសម្រាប់ផ្នែកឃុំខ្លួននៃសាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងករណី អៀង សារី[៩]។

៥. នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់អំណះអំណាងដោយផ្ទាល់មាត់របស់មេធាវីការពារក្ដីទាំងបីក្រុម និងសហព្រះរាជអាជ្ញា[១០]។ អង្គជំនុំជម្រះបានស្នើឱ្យភាគីនានាឆ្លើយទៅនឹងសំណួរពីរខាងក្រោមនេះ៖

១. តើអ្វីទៅដែលជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដោយសារតែសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ មិនមាននូវសំអាងហេតុនោះ?
២. ហេតុអ្វីបានជាមេធាវីការពារក្ដីនិយាយថា ការដោះលែងភ្លាមៗ គឺជាសំណងមួយដ៏សមរម្យសម្រាប់ដោះស្រាយនូវការរំលោភលើសិទ្ធិរបស់ជនជាប់ចោទនោះ?[១១]

៦. ក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះបានស្នើឱ្យមេធាវីការពារក្ដីទាំងបីក្រុម និងសហព្រះរាជអាជ្ញា បញ្ជាក់ថាតើមេធាវីការពារក្ដីទាំងបីក្រុម និងសហព្រះរាជអាជ្ញាយល់ថាបុរេលក្ខខណ្ឌសម្រាប់ការរក្សាការឃុំខ្លួនបណ្ដោះអាសន្ន ផ្អែកតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងនៅតែមានអត្ថិភាពដែរ ឬយ៉ាងណា និងថាតើជនជាប់ចោទទាំងបីរូបមានការផ្លាស់ប្ដូរស្ថានភាពដែរ ឬយ៉ាងណា[១២]។

---

របស់ អៀង ធីរិទ្ធ និងខ្លួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនបណ្ដោះអាសន្ន" ឯកសារលេខ D427/3/13 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

[៨] "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារលេខ D427/4/15 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

[៩] "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្ដោះអាសន្ន" ឯកសារលេខ D427/1/27 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១។

[១០] ប្រតិចារិក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១។

[១១] "ដីកាកំណត់កាលបរិច្ឆេទសវនាការរួមលើសំណើសុំឱ្យដោះលែង" ឯកសារលេខ E26 ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១១ ទំព័រ២។ ប្រតិចារិក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៧-៩។

[១២] ប្រតិចារិក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៣០-៣១។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

៧. នៅក្នុងអនុស្សរណៈអន្តរការិយាល័យ ដែលបានដាក់នៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យអង្គបុរេជំនុំជម្រះធ្វើការពន្យល់ ថាតើហេតុអ្វីបានជាអង្គបុរេជំនុំជម្រះមិនបានផ្តល់សំអាងហេតុនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ នៅពេលដែលខ្លួនចេញសាលដីកានេះ ហើយថាតើអង្គបុរេជំនុំជម្រះនឹងចេញសំអាងហេតុពេញលេញ ទាក់ទងនឹង នួន ជា និង អៀង ធីរិទ្ធ នៅពេលណា[១៣]។

៨. អង្គបុរេជំនុំជម្រះបានឆ្លើយតប ដោយបានជូនដំណឹងថា អង្គបុរេជំនុំជម្រះនឹងចេញសំអាងហេតុពេញលេញរបស់ខ្លួនជាភាសាអង់គ្លេស "នៅដើមសប្តាហ៍ក្រោយ"[១៤]។ នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ អ.ប.ជ បានចេញសំអាងហេតុរបស់ខ្លួនលើដីកាដំណោះស្រាយទាក់ទងនឹងករណី នួន ជា និង អៀង ធីរិទ្ធ[១៥]។

## ៣. សារណា

## ៣.១ សំណើរបស់មេធាវីការពារក្តី

### *៣.១.១ កង្វះមូលដ្ឋានច្បាប់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន*

៩. ជនជាប់ចោទទាំងបី បានលើកឡើងថា ការឃុំខ្លួនពួកគាត់បណ្តោះអាសន្ន មិនមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ ហេតុដូច្នេះជនជាប់ចោទទាំងបី បានស្នើសុំឱ្យអង្គជំនុំជម្រះដោះលែងពួកគាត់ឱ្យមានសេរីភាពភ្លាម។ ក្រុមមេធាវីការពារក្តី នួន ជា និងក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ បានលើកឡើងថា សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយមិនមានសំអាងហេតុ ដូចដែលតម្រូវដោយវិធាន ៧៧(១៤) នោះទេ។ ដូច្នេះសាលដីកាទាំងនេះ មិនអាចមានតម្លៃជាសាលដីកាផ្អែកតាមវិធាន ៦៨(២) និង (៣) ឡើយ។ បន្ថែមពីលើនេះ ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ ស.ច.ស ដែលបានចេញក្នុងពេលជាមួយគ្នានឹងដីកាដំណោះ ស្រាយនៅ

---

[១៣] "ការស្នើសុំព័ត៌មានទាក់ទងនឹងសំអាងហេតុសម្រាប់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងសេចក្តីសម្រេចអំពីការឃុំខ្លួននៅក្នុងសវនាការសំណុំរឿង ០០២" ឯកសារលេខ E32 ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១។

[១៤] "ចម្លើយតបទៅនឹងអនុស្សរណៈអន្តរការិយាល័យចេញដោយអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៤ ខែ កុម្ភៈ ឆ្នាំ ២០១១" ឯកសារលេខ D427/3/14 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១១ ("ចម្លើយតប អ.ប.ជ")។

[១៥] "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារលេខ D427/2 /15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

00644904



ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ បានផុតកំណត់ក្រោយពីរយៈពេលបួនខែ និងមានតែសេចក្តីសម្រេចត្រឹមត្រូវរបស់ អ.ប.ជ ផ្អែកតាមវិធាន៦៨(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះដែលអាចពន្យាររយៈពេលបានតទៅទៀត។ ក្នុងករណីដែលសាលដីកា អ.ប.ជ មិនមានលក្ខណៈគ្រប់គ្រាន់នោះ វាមិនមានមូលដ្ឋានច្បាប់ក្នុងការបន្តឃុំខ្លួនជនជាប់ចោទនោះទេ[១៦]។ បន្ថែមពីលើនេះ ការខកខានក្នុងការចេញសំអាងហេតុសម្រាប់ផ្នែកឃុំខ្លួននៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ ធ្វើឱ្យការឃុំខ្លួនបណ្តោះអាសន្នចាប់តាំងពីថ្ងៃទី ១៣ ខែ មករា រហូតមកទល់ពេលនេះ មិនមានមូលដ្ឋានច្បាប់នោះទេ។

១០. មេធាវីការពារក្តី នួន ជា បានលើកឡើងពីបទដ្ឋានជំនុំជម្រះដោយយុត្តិធម៌ជាលក្ខណៈអន្តរជាតិ និងគោលការណ៍នីត្យានុកូលភាព ដើម្បីគាំទ្រការតវ៉ារបស់ខ្លួនដែលថា សំអាងហេតុ គឺជាផ្នែកមួយដ៏សំខាន់នៃសាលដីកា ក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក[១៧]។ ជាចុងក្រោយ មេធាវីការពារក្តី នួន ជា បានចោទប្រកាន់អំពីការបំពារបំពានគោលការណ៍ *ដំណោះស្រាយខ្ពស់បំផុត (ultimum remedium)* ដោយផ្អែកលើមូលដ្ឋានថា ស.ច.ស និង អ.ប.ជ បានបន្តប្រើប្រាស់ការឃុំខ្លួនជាគោលដៅមួយរបស់ខ្លួន ជាជាងប្រើប្រាស់ការឃុំខ្លួននេះជាវិធានការពិសេសមួយ[១៨]។

១១. មេធាវីការពារក្តី ខៀវ សំផន បានតវ៉ាថា វិធាន៦៨(៣) នៃវិធានផ្ទៃក្នុង នៅពេលអានស្របគ្នាជាមួយនឹងមាត្រា៣០៥ និងមាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បង្កើតនូវលក្ខខណ្ឌតម្រូវដាច់ខាតថា ជនជាប់ចោទដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែនាំមកបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលបួនខែ ក្រោយពីពេល

---

[១៦] "សំណើសុំដោះលែង នួន ជា ជាបន្ទាន់" ឯកសារលេខ E19 ចុះថ្ងៃ ១៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ១២-១៥។ "សំណើបន្ទាន់ដើម្បីឱ្យដោះលែង អ្នកស្រី អៀង ធីរិទ្ធ ដោយឥតបង្អង់" ឯកសារលេខ E21 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ១១-១២។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ១២-១៤, ១៩, ៣០-៣១ (ទាញសំអាងហេតុផងដែរពីមាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អនុលោមតាមបទប្បញ្ញត្តិទាំងនេះ ជនជាប់ចោទត្រូវតែដោះ-លែងឱ្យមានសេរីភាព បន្ទាប់ពីរយៈពេលបួនខែ ប្រសិនបើគាត់មិនបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង)។

[១៧] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ១៩-២០, ២២-២៣។

[១៨] "សំណើសុំដោះលែង នួន ជា ជាបន្ទាន់" ឯកសារ E19 ចុះថ្ងៃ ១៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ៦។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៦៥។

ចេញដីកាដំណោះស្រាយ[១៩]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានតបវិញថា ក្រោយពីពេលដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ រយៈពេលបួនខែនេះ ត្រូវចាប់ផ្តើមរាប់ពីពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានសម្រេច និងនៅពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរ។ នៅក្នុងបរិបទបច្ចុប្បន្ននេះ ថិរវេលាកំណត់នេះ នៅបន្តរាប់នៅឡើយ[២០]។

### *៣.១.២ ការរំលោភលើសិទ្ធិ និងសំណង*

១២. ឆ្លើយតបទៅនឹងសំណួរដែលបានចោទសួរដោយអង្គជំនុំជម្រះ មេធាវីការពារក្តីក្រុម នួន ជា បានលើកឡើងពីការរំលោភលើសិទ្ធិ ដែលទាក់ទងនឹងលទ្ធភាពរបស់ខ្លួនក្នុងការរៀបចំអញ្ញត្រកម្ម ដោយសារតែសាលដីការបស់ អ.ប.ជ ពុំមាននូវសំអាងហេតុនោះ។ មេធាវីការពារក្តីមានការលំបាកខ្លាំង ជាពិសេស ទាក់ទងនឹងអញ្ញត្រកម្មលើបញ្ហាយុត្តាធិការដែលសំអាងហេតុនៃបញ្ហានេះ នៅមិនទាន់មាននៅឡើយ។ មេធាវីការពារក្តីក្រុម នួន ជា តវ៉ាបន្ថែមថា ការខកខានរបស់តុលាការក្នុងការអនុវត្តតាមច្បាប់ឲ្យបានត្រឹមត្រូវនោះ គឺជាការរំលោភលើសិទ្ធិ ហើយការរំលោភសិទ្ធិនេះអាចនឹងជួសជុលវិញបានតាមរយៈការដោះលែងឲ្យមានសេរីភាពភ្លាមតែប៉ុណ្ណោះ[២១]។

### *៣.១.៣. លក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង*

១៣. ក្រុមមេធាវីការពារក្តី បានផ្អែកលើការរួមបញ្ចូលគ្នានៃកត្តានានាខាងក្រោម ដើម្បីបង្ហាញថា បុរេលក្ខខណ្ឌសម្រាប់ការឃុំខ្លួន ដែលមានចែងនៅក្នុងវិធាន៦៣(៣) មិនត្រូវបានបំពេញ។ ក្រុមមេធាវីការពារក្តីលើកឡើងថា ការបន្តការឃុំខ្លួន មិនមែនជាការចាំបាច់ដើម្បីធានាឲ្យមានវត្តមានជនជាប់ចោទនៅពេលជំនុំជម្រះទេ ហើយការដោះលែងឲ្យមានសេរីភាព ក៏មិនគំរាមកំហែងដល់ជនជាប់ចោទ ឬសណ្តាប់ធ្នាប់សាធារណៈនោះដែរ។ បន្ថែមពីលើនេះ មិនមានការ

---

[១៩] "សំណើសុំដោះលែងឲ្យមានសេរីភាព យោងទៅវិធាន៨២(៣) នៃវិធានផ្ទៃក្នុង" ឯកសារ E18 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ១៩, ២១ និង២៤។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ២៧-៣០។

[២០] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៤៨-៥១ (ទាញសំអាងហេតុ វិធាន៦៨(៣) នៃវិធានផ្ទៃក្នុង និងមាត្រា២៤៧ ដល់២៥០ និង២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[២១] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ១៣-១៨។ មេធាវីការពារក្តីផ្សេងទៀត មិនបានឆ្លើយដោយផ្ទាល់ទៅនឹងសំណួរទាំងពីរដែលលើកឡើងដោយអង្គជំនុំជម្រះនោះទេ។ (*សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ២៦-២៨)។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C

ចង្អុលបង្ហាញថា ជនជាប់ចោទបានព្យាយាមគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ដែលសាក្សី ឬជនរងគ្រោះភាគច្រើន ត្រូវបានស្តាប់យកចម្លើយរួចរាល់ហើយ ក្នុងអំឡុងពេលនៃការស៊ើបសួររបស់តុលាការ[២២]។ ជាងនេះទៅទៀត យុត្តិសាស្ត្រអន្តរជាតិ បង្ហាញថា យុត្តិកម្មសម្រាប់បន្តការឃុំខ្លួន ត្រូវបានកាត់បន្ថយបន្តិចម្តងៗរហូតមកទល់ពេលនេះ។ អាស្រ័យហេតុនេះ ការរក្សាការឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលវែង ត្រូវតែធ្វើយុត្តិកម្មតាមរយៈសំអាងហេតុត្រឹមត្រូវ[២៣]។ ជាចុងក្រោយ ជម្រើសផ្សេងៗទៀត ដូចជាការឃុំខ្លួនក្នុងផ្ទះ ក៏អាចធានាសន្តិសុខគ្រប់យ៉ាងបានដែរ[២៤]។

### *៣.២ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា*

១៤. សហព្រះរាជអាជ្ញា ប្រឆាំងនឹងសំណើសុំដោះលែងឱ្យមានសេរីភាព។

#### *៣.២.១ ភាពមិនអាចទទួលយកបាននៃសំណើសុំ (នួន ជា)*

១៥. សហព្រះរាជអាជ្ញា សន្និដ្ឋានថា សំណើសុំរបស់ នួន ជា មិនអាចទទួលបានទេ ដោយសារតែសំណើសុំឱ្យពិនិត្យមើលឡើងវិញអំពីសុពលភាពនៃសាលដីកានានាលើដីកាដំណោះស្រាយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង មិនមែនជាស្ថាប័នសម្រាប់ប្តឹងឧទ្ធរណ៍ ហើយវិធាន៧៧(១៣) ចែងថា សាលដីកានានារបស់ អ.ប.ជ បិទផ្លូវតវ៉ា[២៥]។ នួន ជា ជំទាស់នឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការកំណត់ចរិតលក្ខណៈនៃសំណើ

---

[២២] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៣០-៣៥ (មេធាវីការពារ នួន ជា) ទំព័រ៣៥-៣៦ (មេធាវីការពារ ខៀវ សំផន) (កត់សម្គាល់ឃើញថា ការដោះលែងឱ្យមានសេរីភាព មិនមានហានិភ័យចំពោះសុវត្ថិភាពរបស់ជនជាប់ចោទ ដោយពិនិត្យមើលឃើញថាគ្មានអំពើហិង្សាក្នុងអំឡុងពេលទស្សនកិច្ចរបស់មន្ត្រី អ.វ.ត.ក ទៅកាន់ខេត្តប៉ៃលិន)។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៣៦-៣៨ (អៀង ធីរិទ្ធ) ហានិភ័យចំពោះសាក្សី មិនអាចមាននោះទេ ដោយសារតែការស៊ើបអង្កេតរបស់តុលាការត្រូវបានបញ្ចប់ ហើយជនជាប់ចោទទំនងជាមិនធ្វើឱ្យមានការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ដោយសារពួកគាត់មានអាយុចាស់ជរា និងមានសុខភាពទ្រុឌទ្រោម)។

[២៣] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៣២-៣៣ (ក្រុមមេធាវីការពារក្តី នួន ជា)

[២៤] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៣៧-៣៨ (អៀង ធីរិទ្ធ)។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៦៥-៧០ (ខៀវ សំផន)។

[២៥] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤០-៤១។

TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · E C C C

សុំឱ្យដោះលែងមានសេរីភាពរបស់គាត់ ដោយគាត់បានបញ្ជាក់ថា សំណើសុំត្រូវបានធ្វើឡើង ដោយអនុលោមតាមវិធាន ៨២(៣) នៃវិធានផ្ទៃក្នុង[២៦]។

### *៣.២.២ ខ្លឹមសារនៃពាក្យសុំ និងការរំលោភលើសិទ្ធិ (នួន ជា)*

១៦. សហព្រះរាជអាជ្ញា ប្រឆាំងនឹងការលើកឡើងដែលថា នួន ជា បានទទួលរងការរំលោភលើសិទ្ធិរបស់គាត់ ដោយសារការខកខានរបស់ អ.ប.ជ ក្នុងការចេញសំអាងហេតុសម្រាប់សាលដីកានានា ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ កម្រិតនៃសំអាងហេតុ ដែលតម្រូវឱ្យមាននៅក្នុងសេចក្តីសម្រេចតុលាការ អាស្រ័យលើស្ថានភាពទាំងមូល ដែលក្នុងនោះរួមមានប្រភេទ និងបរិមាណនៃសំអាងហេតុដែលដាក់ដោយភាគីនានា។ នៅក្នុងករណីនេះ នួន ជា មិនបានដាក់សារណាចំពោះមុខ អ.ប.ជ ទាក់ទងនឹងការឃុំខ្លួន អាស្រ័យហេតុនេះ អ.ប.ជ គ្រាន់តែបន្តដីកាឃុំខ្លួនពីមុនរបស់ ស.ច.ស តែប៉ុណ្ណោះ។ ហេតុដូច្នេះ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនជនជាប់ចោទ គឺមានយ៉ាងច្បាស់លាស់ ហើយជាក់ស្តែង ជនជាប់ចោទមិនមានអ្វីត្រូវសង្ស័យនោះទេ ទាក់ទងនឹងការប្រើប្រាស់សំអាងហេតុទាំងនោះធ្វើជាមូលដ្ឋាននៃការឃុំខ្លួន[២៧]។

១៧. ផ្ទុយទៅនឹងគោលការណ៍*ដំណោះស្រាយខ្ពស់បំផុត* សហព្រះរាជអាជ្ញាបានលើកឡើងថា វិធាន ៨២(១)នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់តុលាការ ICTY បានបង្កើតការសន្មតជាមុនថា នៅពេលបុគ្គលម្នាក់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ហើយត្រូវបានឃុំខ្លួនមុនពេលជំនុំជម្រះ បុគ្គលម្នាក់នោះត្រូវតែស្ថិតក្នុងការឃុំខ្លួនបន្ត រហូតដល់អង្គជំនុំជម្រះ ចេញសេចក្តីសម្រេច ឬលើកលែងតែបុគ្គលនោះអាចធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ស្ថានភាពរបស់ខ្លួនមានការប្រែប្រួល ចាប់តាំងពីពេលដែលបុគ្គលនោះបានដាក់សំណើសុំដោះលែងឱ្យមានសេរីភាពចុងក្រោយរបស់គាត់[២៨]។

### *៣.២.៣ សំណាង (នួន ជា និង អៀង ធីរិទ្ធ)*

---

[២៦] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤០-៤១។

[២៧] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៦៤។

[២៨] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤៣-៤៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត,* សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធចោលការដោះលែង Ljubomir Borovčanin ឱ្យមានសេរីភាព អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-05-88-AR65.3) ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ១១-១២។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C E T C

១៨. សហព្រះរាជអាជ្ញា បានតវ៉ាលើការលើកឡើងដែលថា ការដោះលែងឱ្យមានសេរីភាព គឺជាសំណងតែមួយមុខគត់ ឬសមស្រប ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសាលដីការបស់ អ.ប.ជ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ មិនមានសំអាងហេតុគ្រប់គ្រាន់។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល ICTY រកឃើញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY មិនមានសំអាងហេតុគ្រប់គ្រាន់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូល ICTY មិនបានបង្គាប់ឱ្យដោះលែងជនជាប់ចោទឱ្យមានសេរីភាពនោះទេ ប៉ុន្តែអង្គជំនុំជម្រះបានផ្តល់នូវសំអាងហេតុរបស់ខ្លួនដើម្បីធ្វើជាយុត្តិកម្មបន្តការឃុំខ្លួន[២៩]។ សំណងបន្ថែមក្នុងបរិបទនាពេលបច្ចុប្បន្ន គឺការអនុញ្ញាតឱ្យជនជាប់ចោទដាក់សំណើសុំដោះលែងឱ្យមានសេរីភាពជាថ្មី អនុលោមតាមវិធាន៨២(៣) និង៦៣ នៃវិធានផ្ទៃក្នុង[៣០]។ បន្ថែមពីលើនេះ វិការៈនីតិវិធីទាក់ទងនឹងការឃុំខ្លួននៅក្នុងដីកាដំណោះស្រាយ អាចត្រូវបានប៉ះប៉ូវដោយការផ្តល់សំណង តាមរយៈការកាត់បន្ថយចំនួនឆ្នាំនៃការជាប់ទោស ប្រសិនបើតុលាការរកឃើញថាជនជាប់ចោទមានពិរុទ្ធភាព ឬតាមរយៈសំណងហិរញ្ញវត្ថុ ប្រសិនបើតុលាការសម្រេចឱ្យជនជាប់ចោទរួចខ្លួន[៣១]។

### *៣.២.៤ លក្ខខណ្ឌសម្រាប់ឃុំខ្លួនផ្អែកតាមវិធាន ៦៣(៣)*

១៩. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដើម្បីអាចទទួលយកបាន សំណើសុំត្រូវតែបង្ហាញឱ្យឃើញពីការប្រែប្រួលស្ថានភាពរបស់ជនជាប់ចោទ។ សហព្រះរាជអាជ្ញាបានលើកឡើងថា មិនមានការប្រែប្រួលស្ថានភាពនោះទេ។ ផ្ទុយទៅវិញ ការអនុញ្ញាតឱ្យជនជាប់ចោទពិនិត្យមើលសំណុំរឿង និងព័ត៌មានលម្អិតរបស់សាក្សី បានបង្កើននូវហានិភ័យនៃការគាបសង្កត់លើសាក្សី។ ហានិភ័យសន្តិសុខដល់ជនជាប់ចោទ និងដល់សណ្តាប់ធ្នាប់សាធារណៈ ក៏កើតចេញមកពីការកើនឡើងនៃចំណាប់អារម្មណ៍សាធារណជនចំពោះការងាររបស់ អ.វ.ត.ក ផងដែរ[៣២]។

---

[២៩] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤៣-៤៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត,* សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធចោលការដោះលែង Ljubomir Borovčanin ឱ្យមានសេរីភាព អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-05-88-AR65.3) ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ១៣។

[៣០] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៤៤។

[៣១] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៥៣។

[៣២] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤៤-៤៥, ៤៦-៤៨, ៥៤-៥៦។

២០. សហព្រះរាជអាជ្ញាលើកឡើងបន្ថែមថា អនុលោមតាមវិធាន៦៣(៣)(ក) នៃវិធានផ្ទៃក្នុង ការគាំទ្រទៅលើដីកាដំណោះស្រាយ មានន័យថា មានមូលហេតុដែលត្រូវបានរកឃើញ និង ជឿជាក់យ៉ាងច្បាស់ថា ជនជាប់ចោទធ្លាប់បានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់[៣៣]។ ដោយសារតែបទចោទពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដែលនឹងត្រូវផ្តន្ទាទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថាមានពិរុទ្ធនោះ ជនជាប់ចោទទាំងនោះពិតជាមានចេតនារត់គេច ខ្លួនកាន់តែខ្លាំង[៣៤]។

## ៤. សំអាងហេតុ

### ៤.១ ភាពអាចទទួលយកបាន

២១. អង្គជំនុំជម្រះសាលាដំបូងពុំមានសមត្ថកិច្ចដើម្បីពិនិត្យឡើងវិញ លើសេចក្តីសម្រេចរបស់អង្គ- បុរេជំនុំជម្រះឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចក្នុងការវាយតម្លៃថាតើខ្លួន បានទទួលសំណុំរឿងដែលមានសុពលភាពដែរ ឬទេ តាមរយៈសាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់អង្គបុរេជំនុំជម្រះ ដែលតម្កល់ការចោទប្រកាន់ប្រឆាំងនឹង ជនជាប់ចោទនោះ ហើយអង្គជំនុំជម្រះក៏មានកាតព្វកិច្ចក្នុងការវាយតម្លៃថាតើសាលដីកាទាំង- នេះមានវិការៈផ្នែកនីតិវិធី ឬមិនមាន ដែលវាអាចបណ្តាលឲ្យប៉ះពាល់ដល់ភាពស្របច្បាប់នៃ ការឃុំខ្លួនជនជាប់ចោទដោយផ្អែកលើផ្នែកដែលសម្រេចពីការឃុំខ្លួនរបស់សាលដីកាទាំងនេះ។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា អនុលោមតាមវិធាន ៨២(២) អង្គជំនុំជម្រះសាលាដំបូងអាច "បង្គាប់ឲ្យដោះលែងជនជាប់ចោទ ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងករណីចាំបាច់ ឬបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទបាន ស្របតាមវិធានផ្ទៃក្នុងនេះ គ្រប់ពេលនៃ កិច្ចដំណើរការនីតិវិធី "។

---

[៣៣] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៤៥-៤៧ (នួន ជា) (ចោទប្រកាន់ថា នួន ជា បានដាក់សម្ពាធលើ ឌុច ដើម្បីឲ្យកែចម្លើយសារភាពមន្ទីរ ស-២១ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបំផ្លាញចោលភស្តុតាងដែលបង្ហាញថា គាត់មានហានិភ័យក្នុងការគាបសង្កត់លើសាក្សី ឬជ្រៀតជ្រែកភស្តុតាង)។ នួន ជា បានតបវិញថា មិនមានភស្តុតាងនៃការ ទាក់ទងមិនសមស្របណាមួយរបស់គាត់ជាមួយសាក្សីនានា ឬមានអង្គហេតុណាមួយនៃការធ្វើឲ្យខូចដល់សណ្តាប់ធ្នាប់ សាធារណៈ ក្នុងការធ្វើយុត្តិកម្មចំពោះការឃុំខ្លួនរបស់គាត់នោះទេ។ (ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៣១-៣៥, ៥៩-៦២)។

[៣៤] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ទំព័រ៤៦-៤៧។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

២២. អង្គជំនុំជម្រះកត់សម្គាល់ថា សំណើសុំខ្លះក្នុងចំណោមសំណើសុំទាំងនោះ បានលើកឡើងនូវបញ្ហាស្រដៀងគ្នា ដូច្នេះហើយអង្គជំនុំជម្រះត្រូវដោះស្រាយសំណើសុំទាំងនោះរួមគ្នាតែម្តង។

## ៤.២ កាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់តុលាការ (នួន ជា និង អៀង ធីរិទ្ធ)

២៣. ក្នុងការពិចារណាអំពីការលើកឡើងនៅក្នុងពាក្យសុំរបស់ នួន ជា និង អៀង ធីរិទ្ធ ដែលថាសាលដីកាលើដីកាដំណោះស្រាយពុំមានលក្ខណៈគ្រប់គ្រាន់ជាសាលដីកា អនុលោមតាមវិធាន ៦៨(២) និង (៣) ដោយសារសាលដីកាទាំងនោះពុំមានសំអាងហេតុនោះ អង្គជំនុំជម្រះបានពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងកាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់តុលាការ។

### *៤.២.១ ច្បាប់ជាធរមាន*

### *៤.២.១.១ ច្បាប់កម្ពុជា និងវិធានផ្ទៃក្នុង អ.វ.ត.ក*

២៤. កាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុគឺមានចែងនៅក្នុងបទប្បញ្ញត្តិមួយចំនួននៃច្បាប់កម្ពុជា[៣៥]។ ទោះបីជាវិធានផ្ទៃក្នុងពុំមានចែងអំពីលក្ខខណ្ឌទូទៅក្នុងការផ្តល់សំអាងហេតុចំពោះសេចក្តី-សម្រេចរបស់តុលាការក៏ដោយ ក៏វិធាន ៧៧(១៤) តម្រូវឱ្យ អ.ប.ជ ផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចដែលបានចេញ ដោយផ្អែកតាមវិធាននេះដែរ[៣៦]។ ដូច្នេះ វាពិតណាស់ដែលថាសំអាងហេតុគឺជាភាពចាំបាច់មួយនៃសេចក្តីសម្រេច ដោយផ្អែកតាមច្បាប់កម្ពុជា និងវិធានផ្ទៃក្នុង។ លើសពីនេះទៀត ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង កំណត់យ៉ាងច្បាស់លាស់នូវកាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចបង្គាប់ឱ្យឃុំខ្លួន និងពន្យារ

---

[៣៥] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (“CCP”), មាត្រា ២០៦ (ដីកាបង្គាប់ឱ្យឃុំខ្លួន), ២៤៧ (ដីកាដំណោះស្រាយ), ៣៥៧ (សាលក្រម) និង ៤១៩ (រៀបរាប់ការខ្វះសំអាងហេតុថាជាមូលដ្ឋានមួយក្នុងការស្នើសុំបដិសេធ សេចក្តីសម្រេចនៅចំពោះមុខតុលាការកំពូល)។

[៣៦] វិធាន៧៧(១៤) ចែងថា “សេចក្តីសម្រេចទាំងអស់ស្ថិតនៅក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ”។ កាតព្វកិច្ចនេះគឺអនុវត្តចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ [illegible] វិធាន ៧៤(៣)(ក) ទេ (បណ្តឹងឧទ្ធរណ៍លើយុត្តាធិការ)។

ពេលការឃុំខ្លួន[៣៧]។ ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក ជាទូទៅពុំមានចែងអំពីផលវិបាកនៃការយឺតយ៉ាវក្នុងការផ្ដល់សំអាងហេតុនោះទេ។

### *៤.២.១.២. បទដ្ឋានអន្តរជាតិ*

២៥. អង្គជំនុំជម្រះក៏បានពិនិត្យផងដែរលើបទដ្ឋានអន្តរជាតិ ដើម្បីកំណត់អំពីគោលបំណងដែលជាមូលដ្ឋាននៃលក្ខខណ្ឌ ដែលតម្រូវថាសេចក្ដីសម្រេចរបស់តុលាការ ត្រូវតែមានសំអាងហេតុ។ សំអាងហេតុ ចំពោះសេចក្ដីសម្រេចរបស់តុលាការ ត្រូវបានចាត់ទុកថាជាធាតុផ្សំដ៏សំខាន់មួយនៃសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ដូចដែលត្រូវបានការពារដោយមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ បទប្បញ្ញត្តិនេះ ដែលត្រូវបានយោងយ៉ាងជាក់លាក់នៅក្នុងមាត្រា ១២ នៃកិច្ចព្រមព្រៀងរវាង

---

[៣៧] ទាក់ទងនឹងសាលដីកាស្ដីពីការឃុំខ្លួន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងវិធានផ្ទៃក្នុងបង្ហាញថាសំអាងហេតុគួរតែត្រូវបានលើកឡើងក្នុងពេលជាមួយគ្នានឹងពេលចេញដីកាឃុំខ្លួន៖ *សូមមើល* វិធាន៤៤(២) នៃវិធានផ្ទៃក្នុង (ដីកាបង្គាប់ឱ្យចាប់ខ្លួន/ឃុំខ្លួន នៅក្នុងករណីល្បួចរត់គេចខ្លួន) ៥១(១) និង (៣) (ការឃាត់ខ្លួន និងពន្យារពេល), ៦៣(១)(ខ) (ស.ច.ស សម្រេចឃុំខ្លួនបណ្ដោះអាសន្ន ៦៣(៧) (ស.ច.ស សម្រេចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន), ៦៤(២) (ស.ច.ស សម្រេចលើសំណើសុំដោះលែង), ៦៨(១) (ដីកាសម្រេចឃុំខ្លួនរបស់ ស.ច.ស នៅក្នុងដីកាដំណោះស្រាយ), ១១១ (ដីកាសម្រេចឃុំខ្លួនរបស់ អ.ជ.ត.ក)។ *សូមមើលបន្ត* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២០៦ (ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នចេញដោយសហចៅក្រមស៊ើបសួរ), ២១០ (ការពន្យារការឃុំខ្លួនបណ្ដោះអាសន្នដោយចៅក្រមស៊ើបសួរ នៅក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ), ២១១ (ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នដោយចៅក្រមស៊ើបសួរ) និង ២៧៨ (ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់សភាស៊ើបសួរ) ("កាលណាសភាស៊ើបសួរបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន សភាស៊ើបសួរត្រូវ*[មាន]*សំអាងហេតុនៅក្នុងសាលដីការបស់ខ្លួន ដោយយោងតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ)។

រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ[៣៨] ត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងមាត្រា ១៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("អនុសញ្ញា")[៣៩]។

២៦. ក្នុងការបកស្រាយបទប្បញ្ញត្តិទាំងនេះ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ("តុលាការ ECHR") បានបញ្ជាក់ជារឿយៗ និងដោយស៊ីសង្វាក់គ្នាថា តុលាការត្រូវផ្តល់សំអាងហេតុក្នុងរាល់សេចក្តីសម្រេចរបស់ខ្លួន[៤០]។ កាតព្វកិច្ចនេះត្រូវតែបំពេញ ដោយសារ គោលបំណងដូចខាងក្រោម ៖

ក) ការពារភាគីឱ្យចាកផុតពីការទទួលនូវការសម្រេចសេចក្តីមួយ តាមតែទំនើងចិត្ត និងការពារសច្ចភាពផ្លូវច្បាប់[៤១]

ខ) ធានាថា ជនជាប់ចោទ និងសាធារណជន ពិតជាបានយល់អំពីសេចក្តីសម្រេច និងបង្ហាញភាគីថា តុលាការពិតជាបានស្តាប់ទឡ្ហីករណ៍ទាំងអស់ដែលពួកគេបានលើកឡើង[៤២]

---

[៣៨] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, 999 UNTS 171 ("ICCPR"), មាត្រា ១៤(១) (ចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី")។ "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និង ចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ មាត្រា១២។

[៣៩] អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (ETS 5/213 UNTS 222, ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០)។

[៤០] *រឿងក្តី Ruiz Torija តទល់នឹង Spain*, សាលក្រមរបស់តុលាការ ECHR (លេខ. 18390/91), ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៤, កថាខណ្ឌ២៩។ *រឿងក្តី Suominen តទល់នឹង Finland*, សាលក្រមរបស់តុលាការ ECHR (លេខ. 37801/97), ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌ៣៤។

[៤១] *រឿងក្តី Khudoyorov តទល់នឹង Russia*, សាលក្រមរបស់តុលាការ ECHR (លេខ. 6847/02), ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ១២៥, ១៣១, ១៣៥-១៣៦, ១៤៦។ *រឿងក្តី Stašaitis តទល់នឹង Lithuania*, សាលក្រមរបស់តុលាការ ECHR (លេខ. 47679/99), ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០២, កថាខណ្ឌ៦៧។

[៤២] *រឿងក្តី Taxquet តទល់នឹង Belgium*, សាលក្រមរបស់តុលាការ ECHR (លេខ. 926/05), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ៩០-៩៣។ *រឿងក្តី Suominen តទល់នឹង Finland*, សាលក្រម, ECHR (លេខ. 37801/97), ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌ៣៧។

គ) អនុញ្ញាតឱ្យមានការត្រួតពិនិត្យជាសាធារណៈលើកិច្ចការរដ្ឋបាលតុលាការ និងធានាថា តុលាការបង្ហាញនូវការយកចិត្តទុកដាក់ជាពិសេសនៅក្នុងការអនុវត្តដំណើរការនីតិវិធី[៤៣]

ឃ) ពង្រឹងចៅក្រមឱ្យអនុវត្តកាតព្វកិច្ច ក្នុងការបង្ហាញសំអាងហេតុរបស់ខ្លួន ដោយផ្អែកទៅលើទឡ្ហីករណ៍ជាសត្យានុម័ត[៤៤] និង

ង) ធានានូវយន្តការប្តឹងឧទ្ធរណ៍ ដោយផ្តល់លទ្ធភាពឱ្យភាគីប្តឹងឧទ្ធរណ៍ និងដោយអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់ ឬសាលាឧទ្ធរណ៍[៤៥]។

២៧. ទោះបីជាគោលបំណងទាំងនេះត្រូវបានបំពេញយ៉ាងពិតប្រាកដ នៅពេលសំអាងហេតុ ត្រូវបានផ្តល់នៅក្នុងសេចក្តីសម្រេចយ៉ាងណាក៏ដោយ ក៏វិសាលភាពនៃកាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់តុលាការ មានលក្ខណៈខុសគ្នា អាស្រ័យទៅលើចរិតលក្ខណៈនៃសេចក្តីសម្រេចនោះ និងកាលៈទេសៈនៃករណីពិសេសនីមួយៗ[៤៦]។ ការប្រតិបត្តិតាម

---

[៤៣] *រឿងក្តី Suominen តទល់នឹង Finland,* សាលក្រមរបស់តុលាការ ECHR (លេខ. 37801/97), ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌ៣៧។ *រឿងក្តី Khudoyorov តទល់នឹង Russia,* សាលក្រមរបស់តុលាការ ECHR (លេខ. 6847/02), ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ១៧៤។ *សូមមើលផងដែរ រឿងក្តី Abdeel Keerem Hassan Aboushanif តទល់នឹង Norway,* ទស្សនៈ, គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីអត្ថាធិប្បាយលេខ 1542/2007, កថាខណ្ឌ៧.២ ទាក់ទងនឹងកង្វះខាតហេតុផលនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍។

[៤៤] *រឿងក្តី Taxquet តទល់នឹង Belgium*, សាលក្រម, ECHR (លេខ. 926/05), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ ៩១។

[៤៥] *រឿងក្តី Taxquet តទល់នឹង Belgium*, សាលក្រមរបស់តុលាការ ECHR (លេខ. 926/05), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ៩២។ *Suominen តទល់នឹង Finland*, សាលក្រមរបស់តុលាការ ECHR (លេខ. 37801/97), ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌ៣៧-៣៨។ *រឿងក្តី Khudoyorov តទល់នឹង Russia,* សាលក្រម, ECHR (លេខ. 6847/02), ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ១៧២។ *រឿងក្តី Hadjianastassiou តទល់នឹង Greece,* សាលក្រមរបស់តុលាការ ECHR (លេខ. 12945/87), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩២, កថាខណ្ឌ៣៣។

[៤៦] *រឿងក្តី Ruiz Torija តទល់នឹង Spain*, សាលក្រម, ECHR (លេខ. 18390/91), ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៤, កថាខណ្ឌ២៩។ *រឿងក្តី Suominen តទល់នឹង Finland,* សាលក្រមរបស់តុលាការ ECHR (លេខ. 37801/97), ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌ៣៤។ *រឿងក្តី Taxquet តទល់នឹង Belgium,* សាលក្រមរបស់តុលាការ ECHR (លេខ. 926/05), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ៩១, ៩៣ ("មាត្រា៦ កថាខណ្ឌ១ តម្រូវឱ្យតុលាការចេញ

លក្ខខណ្ឌនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ក៏ត្រូវបានវាយតម្លៃផងដែរដោយពិចារណាលើដំណើរការនីតិវិធីទាំងមូល និងបរិបទជាក់លាក់នៃប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធ[៤៧]។

### *៤២២ សំអាងហេតុ*

២៨. ទោះបីជាមានការពិចារណាដូចខាងលើយ៉ាងណាក៏ដោយ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានចេញដំបូងនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ដោយពុំមានសំអាងហេតុ។ ក្នុងការផ្តល់យុត្តិកម្មរបស់ខ្លួនចំពោះការយឺតយ៉ាវក្នុងការចេញសំអាងហេតុនេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់នូវឧបសគ្គចំពោះមុខ ទំហំ និងភាពស្មុគស្មាញនៃដំណើរការនីតិវិធី ហើយអង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា សិទ្ធិរបស់ភាគីប្រាកដជានឹងត្រូវ "រងការប៉ះពាល់យ៉ាងជាក់ស្តែងបំផុតដោយសារការមិនបានវាយតម្លៃឲ្យបានហ្មត់ចត់ត្រឹមត្រូវ និងមិនបានដោះស្រាយចំពោះរាល់បញ្ហាទាំងអស់ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍"[៤៨]។ សំអាងហេតុទាំងនេះត្រូវបានផ្តល់ជូន ៣២ ថ្ងៃក្រោយមក[៤៩]។

---

សំអាងហេតុនៅក្នុងសាលក្រម/សាលដីកា ប៉ុន្តែមិនអាចចាត់ទុកថាជាលក្ខខណ្ឌតម្រូវសម្រាប់ការឆ្លើយលម្អិតទៅនឹងទឡ្ហីករណ៍ទាំងនោះទេ។ កម្រិតក្នុងការអនុវត្តកាតព្វកិច្ចផ្តល់សំអាងហេតុ អាចមានភាពខុសៗគ្នា អាស្រ័យលើប្រភេទនៃសេចក្តីសម្រេច។ វាកាន់តែចាំបាច់ក្នុងការពិចារណាភាពផ្សេងៗគ្នានៃសារណា ដែលដើមបណ្តឹងអាចដាក់នៅចំពោះមុខតុលាការ និងភាពខុសគ្នាដែលមាននៅក្នុងរដ្ឋភាគីដែលទាក់ទងនឹងបទប្បញ្ញត្តិច្បាប់ ច្បាប់ទំនៀមទម្លាប់ គតិច្បាប់ និងការធ្វើបទបង្ហាញ និងការធ្វើសេចក្តីព្រាងសេចក្តីសម្រេច។ ដូច្នេះហើយបានជាមានសំណួរចោទសួរ ថាតើតុលាការដែលខកខនក្នុងការបំពេញនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការចេញនូវសេចក្តីសម្រេចដែលមាននូវសំអាងហេតុនោះ អាចធ្វើដូច្នេះដោយផ្អែកទៅតាមកាលៈទេសៈនៃរឿងក្តីបានដែរឬទេ ផ្អែកតាមមាត្រា៦នៃអនុសញ្ញានេះ") ។

[៤៧] ឧទាហរណ៍ តុលាការបានរកឃើញថា អវត្តមាននៃសំអាងហេតុនៅក្នុងសេចក្តីសម្រេច ដោយផ្អែកលើអង្គហេតុដែលថាកំហុសរបស់អ្នកប្តឹង ត្រូវបានសម្រេចដោយគណៈវិនិច្ឆ័យអង្គហេតុ មិនផ្ទុយនឹងអនុសញ្ញានោះទេ៖ *រឿងក្តី R. តទល់នឹង Belgium,* សេចក្តីសម្រេចលើភាពអាចទទួលយកបាន, ECHR (លេខ. 15957/90), ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩២។ *រឿងក្តី Saricតទល់នឹង Denmark,* សេចក្តីសម្រេចលើភាពអាចទទួលយកបាន (លេខ. 31913/96), ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៩៩, ទំព័រ១៤-១៥។ *រឿងក្តី Taxquetតទល់នឹង Belgium*, សាលក្រមរបស់តុលាការ ECHR (លេខ. 926/05), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ៩០, ៩៣។

[៤៨] ទាក់ទងនឹងការខកខានដំបូងរបស់ខ្លួនក្នុងការផ្តល់សំអាងហេតុចំពោះដីកាឃុំខ្លួនបណ្តោះអាសន្ន សូមមើល ចម្លើយតបរបស់ អ.ប.ជ ទំព័រ៣។ ទោះជាយ៉ាងដូច្នេះក្តី សំអាងហេតុគាំទ្រនៃផ្នែករបស់សាលដីកាលើដីកាដំណោះស្រាយនេះ ត្រូវបានចេញនៅរយៈពេលប្រាំបីថ្ងៃក្រោយមក ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនបណ្តោះអាសន្ន", D427/3/13, ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១)។

២៩. អង្គជំនុំជម្រះយល់ឃើញថា ការយឺតយ៉ាវរបស់អង្គបុរេជំនុំជម្រះក្នុងការផ្តល់សំអាងហេតុចំពោះសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍គឺជាវិការៈផ្នែកនីតិវិធី ដែលជាបឋមបានប៉ះពាល់ដល់សុវត្ថិភាពគតិយុត្ត និងសច្ចភាពផ្លូវច្បាប់នៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះត្រូវតែវាយតម្លៃថាតើ វិការៈផ្នែកនីតិវិធីនេះប៉ះពាល់ដល់សុពលភាពនៃសាលដីកាទាំងនេះដែរ ឬយ៉ាងណា។

៣០. ទោះបីជាការខកខានពីដំបូងក្នុងការផ្តល់សំអាងហេតុ បង្កើតបានជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពិចារណាអំពីកាលៈទេសៈជាក់លាក់មួយចំនួនដែលពាក់ព័ន្ធទៅនឹងរឿងក្តីនេះ។

៣១. ជាដំបូង ហើយបើទោះបីជាសំអាងហេតុដែលមានការយឺតយ៉ាវទំនងជាទាក់ទងទៅនឹងសេចក្តីសម្រេចនានា ដែលទាក់ទិនទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទយ៉ាងណាក៏ដោយ ក៏សំអាងហេតុដែលបានបញ្ជាក់នេះ តាមពិតកើតចេញមកពីបណ្តឹងឧទ្ធរណ៍ផ្នែកយុត្តាធិការនៅចំពោះមុខអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៣)(ក)[៥០]។ ទាក់ទងទៅនឹងបញ្ហានេះ ទាំងច្បាប់កម្ពុជា ទាំងវិធានផ្ទៃក្នុងពុំបានចែងអំពីសិទ្ធិរបស់មេធាវីការពារក្តីក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អ.ប.ជ បានអនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍លើបញ្ហានានាដែលចាត់ទុកថាមានលក្ខណៈផ្នែកយុត្តាធិការ។ សេចក្តីសម្រេចរបស់ អ.ប.ជ លើករណីនេះគឺមិនអាចប្តឹងឧទ្ធរណ៍បានឡើយ។ ហើយភាគីនៅតែអាចលើកឡើងនូវទឡ្ហីករណ៍ទាំងឡាយទាក់ទងទៅនឹងផ្នែកយុត្តាធិការដដែលនេះនៅចំពោះមុខ

---

"សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ", D427/4/15, ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១)។

[៤៩] "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារលេខ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។

[៥០] ផ្នែកនៃបណ្តឹងឧទ្ធរណ៍មេធាវីការពារក្តី ដែលបានទទួលជោគជ័យ គឺជាបណ្តឹងឧទ្ធរណ៍ផ្នែកយុត្តាធិការលើចំណុចចង្អៀតនៃច្បាប់ចំនួនពីរ៖ *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ១១ នៃផ្នែកសម្រេចក្តី (ចំណុចច្បាប់ទាំងនេះគឺ ៖ ១. អត្ថិភាពនៃលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលតម្រូវឱ្យមានទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ និង ២. អត្ថិភាពនៃការរំលោភលើផ្លូវភេទថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចន្លោះឆ្នាំ១៩៧៥-១៩៧៩ និងការកំណត់ប្រភេទបទល្មើសនេះថាជា "អំពើអមនុស្សធម៌ផ្សេងទៀត"។

អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់កាលពីដំបូង ចំពោះការប៉ះពាល់ដែលអាចកើតមានចំពោះជនជាប់ចោទ ទាក់ទងទៅនឹងសមត្ថភាពក្នុងការរៀបចំអញ្ញត្រកម្ម ដោយអង្គជំនុំជម្រះបានបញ្ជាក់ថា ការយឺតយ៉ាវក្នុងការចេញសំអាងហេតុអាចផ្តល់នូវមូលដ្ឋានសម្រាប់ការដាក់សេចក្តីសន្និដ្ឋានបន្ថែមនៅក្នុងពេលសមស្រប[៥១]។

៣២. អង្គជំនុំជម្រះកត់សម្គាល់ទៀតថា អ.ប.ជ បានចេញសំអាងហេតុសម្រាប់សាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ទាក់ទងនឹង ខៀវ សំផន ប្រាំបីថ្ងៃ បន្ទាប់ពីបានចេញសាលដីកា និងទាក់ទងនឹង នួន ជា និង អៀង ធីរិទ្ធ ៣២ ថ្ងៃក្រោយមក។ ចំណែកឯការខកខានពុំបានផ្តល់សំអាងហេតុលើផ្នែកឃុំខ្លួន ក៏ត្រូវបានដោះស្រាយនៅថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១១ ហើយដែរ[៥២]។ ដូច្នេះ នៅដំណាក់កាលនេះ ជនជាប់ចោទមិនអាចចោទប្រកាន់ថា ពួកគេត្រូវបានរារាំងមិនឲ្យមានការរៀបចំការការពារខ្លួនប្រកបដោយប្រសិទ្ធភាពបានឡើយ ហើយជាក់ស្តែង ពុំមានអ្វីដែលគួរឲ្យមន្ទិលសង្ស័យឡើយចំពោះបទឧក្រិដ្ឋនានាដែលពួកគេត្រូវបានចោទប្រកាន់ និងលក្ខណៈនៃការចោទប្រកាន់ផ្នែកអង្គហេតុប្រឆាំងនឹងពួកគេនោះ។

៣៣. ពាក់ព័ន្ធទៅនឹងផ្នែកឃុំខ្លួននៃសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងទោះបីជាមានការទទួលស្គាល់អំពីសារៈសំខាន់ជាពិសេសនៃសំអាងហេតុ របស់សាលដីកាប្រភេទនេះយ៉ាងណាក៏ដោយ ក៏យុត្តិសាស្ត្រដូចដែលបានបញ្ជាក់ខាងលើកំណត់ថា មោឃៈភាពដោយស្វ័យប្រវត្តិពុំកើតមានដោយសារតែការខកខានក្នុងការផ្តល់សំអាងហេតុនោះឡើយ[៥៣]។ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃការរំលោភបំពាននេះ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា មូលដ្ឋាននៃការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទត្រូវបានពិនិត្យ

[៥១] "ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24, E27", ឯកសារ E35, ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ២។

[៥២] អង្គជំនុំជម្រះបានកត់សម្គាល់អំពីការបញ្ជាក់របស់អង្គបុរេជំនុំជម្រះដែលថា អង្គបុរេនឹងចេញសំអាងហេតុទៅលើសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាក់ទងនឹងករណីរបស់ អៀង សារី នៅសប្តាហ៍នេះ (ចម្លើយតបរបស់អង្គបុរេជំនុំជម្រះ)។

[៥៣] *រឿងក្តី Taxquet តទល់នឹង Belgium*, សាលក្រមរបស់តុលាការ ECHR (លេខ. 926/05), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ៩០, ៩៣។ *រឿងក្តី R. តទល់នឹង Belgium,* សេចក្តីសម្រេចលើភាពអាចទទួលយកបាន, ECHR (លេខ. 15957/90), ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩២។

ឡើងវិញយ៉ាងទៀងទាត់ និងជារឿយៗនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និង អ.ប.ជ ដោយធានាថា ក្នុងការអនុវត្តជាក់ស្តែង ជនជាប់ចោទដឹងអំពីមូលដ្ឋាននៃការបន្តការឃុំខ្លួនពួកគេ[៥៤]។ លើសពីនេះទៀត និងបើទោះបីជាផ្នែកឃុំខ្លួននៃសាលដីកាលើបណ្តឹងឧទ្ធរណ៍បិទផ្លូវប្តឹងឧទ្ធរណ៍យ៉ាងណាក៏ដោយ ក៏សំណើសុំដោះលែងអាចត្រូវបានលើកឡើងភ្លាមៗនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[៥៥]។

៣៤. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កត្តានានាខាងលើរួមបញ្ចូលគ្នា កំរិតនូវការប៉ះពាល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ដូច្នេះ វិការៈផ្នែកនីតិវិធីដំបូង ពោលគឺការខកខានពុំបានផ្តល់សំអាងហេតុសម្រាប់សាលដីកាលើបណ្តឹងឧទ្ធរណ៍ ត្រូវបានដោះស្រាយដោយការចេញសំអាងហេតុពេញលេញក្រោយមកទៀត។ ហេតុដូច្នេះ អង្គជំនុំជម្រះបានទទួលសំណុំរឿងដោយមានសុពលភាព។

*៤.២.៣.សំណងជាធរមាន*

៣៥. ការពិនិត្យមើលយុត្តិសាស្ត្រអន្តរជាតិពាក់ព័ន្ធបង្ហាញថា វិការៈដែលមាននៅក្នុងសេចក្តីសម្រេចមួយ មិនមែនសុទ្ធតែបណ្តាលឲ្យសេចក្តីសម្រេចនោះគ្មានសុពលភាពដោយស្វ័យប្រវត្តិនោះទេ[៥៦]។ ទោះបីជាមានការរកឃើញថា សាលដីកានានាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយមានវិការៈដោយសារតែការមិនមាននូវសំអាងហេតុភ្លាមៗក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ករណីនេះមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការធ្វើឲ្យសាលដីកាទាំងនោះនិងផ្នែកនៃការឃុំខ្លួនគ្មានសុពលភាពឡើយ។ ផ្អែកតាមសំអាងហេតុដែលលើកឡើងខាងលើ អង្គជំនុំជម្រះយល់ឃើញថា កាលៈទេសៈពិសេសទាំងឡាយនៃករណីនេះមិនអាចជាមូល

---

[៥៤] ដូចបានកត់សម្គាល់ខាងលើ គ្មានជនជាប់ចោទណាម្នាក់នៃជនជាប់ចោទទាំងបីនាក់ដែលបានដាក់សំណើសុំនេះ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នដែលមានចែងក្នុងដីកាដំណោះស្រាយទៅ អ.ប.ជ នោះទេ។ (*យោងខាងលើ,* កថាខណ្ឌ២)។

[៥៥] វិធាន៨២ នៃវិធានផ្ទៃក្នុង។

[៥៦] *សូមមើលឧទាហរណ៍ រឿងក្តី Khudoyorov តទល់នឹង Russia,* សាលក្រមរបស់តុលាការ ECHR (លេខ. 6847/02), ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ 128-129, 132 ("ការរកឃើញបន្តបន្ទាប់ដែលថាតុលាការបានភ័ន្តច្រឡំផ្នែកតាមច្បាប់ជាតិក្នុងការចេញដីកា ការរកឃើញនេះនឹងមិនប៉ះពាល់ជាប្រតិសកម្មដល់សុពលភាពសម្រាប់ចន្លោះពេលវេលានៃការឃុំខ្លួននោះទេ"។ "ការដែលថា វិការៈមួយចំនួននៅក្នុងនីតិវិធីដែលត្រូវបានរកឃើញក្នុងពេលប្តឹងឧទ្ធរណ៍ មិនមែនមានន័យថាការឃុំខ្លួនជាការខុសច្បាប់នោះទេ")។

ហេតុដែលតម្រូវឲ្យមានការជួសជុសសំណងដោយការដោះលែងឲ្យមានសេរីភាពភ្លាមៗនោះទេ[៥៧]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនយល់ស្របជាមួយមេធាវីការពារក្ដីដែលបានលើកឡើងថា ការដោះលែងជនជាប់ចោទឲ្យមានសេរីភាពភ្លាម គឺជាសំណងដែលមានតែមួយគត់ និងសមស្របនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។ អង្គជំនុំជម្រះយល់ឃើញថា ការដោះលែងឲ្យមានសេរីភាព មិនមែនជាសំណងដែលសមាមាត្រទៅនឹងការរំលោភបំពានសិទ្ធិកាលពីដំបូង ដោយសារសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឬសាលដីកាទាក់ទងនឹងផ្នែកនៃការឃុំខ្លួននោះទេ។

៣៦. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចពិចារណាលើសំណងសមស្របផ្សេងទៀត ដែលទាក់ទងនឹងផ្នែកនៃការឃុំខ្លួននៃសាលដីកាលើបណ្ដឹងឧទ្ធរណ៍នៅពេលចុងបញ្ចប់នៃការជំនុំជម្រះ ក្រោយពេលអង្គជំនុំជម្រះស្ដាប់ការលើកឡើងទឡ្ហីករណ៍របស់ភាគីនានា។

## ៤.៣ មូលដ្ឋានច្បាប់សម្រាប់ការឃុំខ្លួនជនជាប់ចោទ

៣៧. ក្រោយពីបានតម្កល់សុពលភាពនៃសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយរួមបញ្ចូលទាំងផ្នែកនៃការឃុំខ្លួនផងនោះ[៥៨] អង្គជំនុំជម្រះបានពិចារណាអំពីមូលដ្ឋានច្បាប់ទាក់ទងនឹងការឃុំខ្លួនជនជាប់ចោទ។

### *៤.៣.១ លក្ខខណ្ឌសម្រាប់ការឃុំខ្លួនផ្អែកតាមវិធាន ៦៣(៣)*

៣៨. នៅក្នុងអំឡុងពេលសវនាការកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ភាគីនានាត្រូវបានស្នើសុំឲ្យឆ្លើយតបថាតើភាគីយល់ឃើញថា បុរេលក្ខខណ្ឌសម្រាប់ការការឃុំខ្លួនបន្តអនុលោមតាមវិធាន៦៣(៣) ត្រូវបានបំពេញដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះក៏បានពិចារណាថា តើមូលដ្ឋាន

---

[៥៧] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ក៏បានបដិសេធពីមុនផងដែរនូវសំណងដោះលែងឲ្យមានសេរីភាព ទោះបីជាខ្លួនបានទទួលស្គាល់អំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ ដែលទាក់ទងនឹងការឃុំខ្លួនក៏ដោយ។ (*រឿងក្ដី Barayagwiza តទល់នឹង រដ្ឋអាជ្ញា*, សាលដីកា (សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិនិត្យឡើងវិញ ឬពិចារណាឡើងវិញ), អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-97-19-AR72), ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ 71, 75)។

[៥៨] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងផ្នែកនៃការឃុំខ្លួន មានលក្ខណៈជាសាលដីកា ផ្អែកតាមវិធាន៦៨(៣)។ ដីកាឃុំខ្លួនរបស់ ស.ច.ស ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ត្រូវបានពន្យារចិរវេលានៃការឃុំខ្លួន ដោយសារសាលដីកាទាំងនេះ អនុលោមតាមវិធាន ៦៨(៣) នៃវិធានផ្ទៃក្នុង។



E C C C B T C
CHAMBRE DE PREMIÈRE INSTANCE

នានាដែលផ្អែកសម្រាប់ឃុំខ្លួនជនជាប់ចោទនៅក្នុងដីកាដំណោះស្រាយ និងសាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍នៅតែបំពេញដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះយល់ឃើញថាក្រោយពីពេលចេញដីកាដំណោះស្រាយ និងការគាំទ្រដោយការបញ្ជូនរឿងទៅជំនុំជម្រះតាមរយៈសាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ វាមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនជាប់ចោទទាំងបីរូប បានប្រព្រឹត្តបទឧក្រិដ្ឋដែលចោទប្រកាន់ អនុលោមតាមវិធាន ៦៣(៣)(ក)។ អង្គជំនុំជម្រះ បានវាយតម្លៃបន្ថែមលើសារណារបស់ភាគីនានា ដែលទាក់ទងនឹងជនជាប់ចោទនីមួយៗដូចខាងក្រោម៖

### *៤.៣.១.១ នួន ជា*

៣៩. សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា នួន ជា ត្រូវតែស្ថិតក្នុងមន្ទីរឃុំឃាំង ដើម្បីធានានូវវត្តមានរបស់គាត់នៅក្នុងដំណើរការជំនុំជម្រះក្តី រារាំងគាត់កុំឱ្យគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬបំផ្លាញភស្តុតាង ការពារសន្តិសុខគាត់ រក្សាសណ្តាប់ធ្នាប់សាធារណៈ[៥៩]។ អង្គជំនុំជម្រះយល់ស្របថា ការឃុំខ្លួនគឺជាការចាំបាច់ដើម្បីធានាថា គាត់នឹងមានវត្តមាននៅក្នុងដំណើរការជំនុំជម្រះក្តី។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ចំពោះ នួន ជា និងទោសដែលអាចនឹងត្រូវផ្តន្ទា ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធនោះ បង្កើតបានជាហានិភ័យកាន់តែខ្លាំងក្នុងការរត់គេចខ្លួន ប្រសិនបើគាត់ត្រូវបានដោះលែង។ ដោយពុំមានព័ត៌មានលម្អិតទាក់ទងនឹងជម្រើសផ្សេងៗទៀតជំនួសឱ្យការឃុំខ្លួនដូចដែលត្រូវបានបង្ហាញនៅក្នុងសវនាការ អង្គជំនុំជម្រះយល់ឃើញថា ការបន្តដាក់ នួន ជា នៅក្នុងមន្ទីរឃុំឃាំងគឺជាមធ្យោបាយតែមួយគត់ដើម្បីទប់ស្កាត់គាត់កុំឱ្យគេចខ្លួន និងធានាថាគាត់នឹងមានវត្តមាននៅពេលជំនុំជម្រះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបញ្ជាឱ្យការឃុំខ្លួន នួន ជា បន្តទៀត ដោយអនុលោមតាមវិធាន ៦៣(៣)(ខ)(iii)។ អង្គជំនុំជម្រះបដិសេធផ្នែកផ្សេងៗទៀតនៃសារណារបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងដើម្បីគាំទ្រដល់ការឃុំខ្លួនបន្ត ដោយផ្អែកលើមូលដ្ឋានខ្វះនូវការបង្ហាញភស្តុតាង។

---

[៥៩] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ (នួន ជា), ទំព័រ ៥៨-៥៩។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ, D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៦២៤។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រេចការបន្តការឃុំខ្លួនបណ្តោះអាសន្ន", D427/3/13, ចុះថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ៥។

00644920



### ៤.៣.១.២. ខៀវ សំផន

៤០. ស.ច.ស និង អ.ប.ជ យល់ឃើញថា ខៀវ សំផន ត្រូវតែស្ថិតក្នុងមន្ទីរឃុំឃាំង ដើម្បីធានាថា គាត់ពិតជាមានវត្តមានពេលសវនាការ ដើម្បីការពារសុវត្ថិភាពរបស់ជនជាប់ចោទ ដើម្បីការពារសណ្ដាប់ធ្នាប់សាធារណៈ និងទប់ស្កាត់ជនជាប់ចោទមិនឱ្យបង្កហានិភ័យ ឬគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬបំផ្លាញភស្តុតាង ប្រសិនបើគាត់ត្រូវបានដោះលែង[៦០]។ អង្គជំនុំជម្រះយល់ឃើញថាការដែល ខៀវ សំផន អាចប្រឈមនឹងការផ្តន្ទាទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធនោះ ខៀវ សំផន អាចមានចេតនាកាន់តែខ្លាំងក្នុងការរត់គេចខ្លួន។ ការបន្តដាក់គាត់នៅក្នុងមន្ទីរឃុំឃាំងគឺជាការចាំបាច់ ដើម្បីធានាថាគាត់នឹងមានវត្តមាននៅគ្រប់ដំណាក់កាលនៃសវនាការ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបញ្ជាឱ្យបន្តការឃុំខ្លួន ខៀវ សំផន បន្តទៀត ដោយអនុលោមតាមវិធាន ៦៣(៣)(ខ)(iii)។ ដោយហេតុផលទាំងនេះ អង្គជំនុំជម្រះបដិសេធផ្នែកផ្សេងៗទៀតនៃសារណារបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងដើម្បីគាំទ្រដល់ការឃុំខ្លួនបន្ត។

### ៤.៣.១.៣. អៀង ធីរិទ្ធ

៤១. ស.ច.ស និង អ.ប.ជ យល់ឃើញថា អៀង ធីរិទ្ធ ត្រូវតែស្ថិតក្នុងមន្ទីរឃុំឃាំងជាបណ្ដោះអាសន្នដើម្បីធានាថា គាត់ពិតជាមានវត្តមានពេលសវនាការ ដើម្បីការពារសណ្ដាប់ធ្នាប់សាធារណៈ និងទប់ស្កាត់ជនជាប់ចោទមិនឱ្យបង្កហានិភ័យ ឬគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬបំផ្លាញភស្តុតាង ប្រសិនបើគាត់ត្រូវបានដោះលែង[៦១]។ ស.ច.ស កត់សម្គាល់ថា ជនជាប់ចោទមានធនធានគ្រប់គ្រាន់ ដែលអាចឱ្យគាត់រត់គេចខ្លួនទៅកាន់ប្រទេសផ្សេងទៀតបាន ហើយជនជាប់ចោទអាចនឹងព្យាយាមរត់គេចពីដំណើរការស្វែងរកយុត្តិធម៌ ដោយជនជាប់ចោទយល់ឃើញថា គាត់អាចនឹងត្រូវប្រឈមមុខនឹងការផ្តន្ទាទោសធ្ងន់ធ្ងរ ក្នុងករណីដែល

---

[៦០] ដីកាដំណោះស្រាយ, D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ 1624។ "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ", D427/4/15, ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ២៩។

[៦១] ដីកាដំណោះស្រាយ, D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ 1624។ "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រេចការបន្តការឃុំខ្លួនបណ្ដោះអាសន្ន", D427/[illegible] 13, ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ៥។

តុលាការរកឃើញថា គាត់មានពិរុទ្ធ[៦២]។ នៅពេលដែលពុំមានព័ត៌មានលម្អិត ទាក់ទងនឹងជម្រើសផ្សេងៗទៀត ជំនួសឲ្យការឃុំខ្លួន ដែលត្រូវបង្ហាញនៅពេលសវនាការ អង្គជំនុំជម្រះយល់ឃើញថា ការបន្តដាក់ អៀង ធីរិទ្ធ នៅក្នុងមន្ទីរឃុំឃាំងគឺជាការចាំបាច់ដើម្បីធានាថា គាត់នឹងមានវត្តមាននៅគ្រប់ដំណាក់កាលនៃសវនាការ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបញ្ជាឲ្យបន្តការឃុំខ្លួន អៀង ធីរិទ្ធ បន្តទៀត ដោយអនុលោមតាមវិធាន ៦៣(៣)(ខ)(iii)។ ដោយហេតុផលទាំងនេះ អង្គជំនុំជម្រះបដិសេធផ្នែកផ្សេងៗទៀតនៃសារណារបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងដើម្បីគាំទ្រដល់ការឃុំខ្លួនបន្ត។

៤២. ដោយពិចារណាលើការខកខានមិនបានជូនដំណឹងជាមុន ដល់ភាគីនានាក្នុងការរៀបចំឲ្យបានគ្រប់គ្រាន់នូវសារណារបស់ខ្លួន ផ្អែកតាមវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះមិនតម្រូវឲ្យមេធាវីការពារក្តីបង្ហាញនូវការប្រែប្រួលស្ថានភាព ផ្អែកតាមវិធាន៨២(៤) នៃវិធានផ្ទៃក្នុងនោះទេ ប្រសិនបើមានសំណើសុំថ្មីឲ្យដោះលែងជនជាប់ចោទឲ្យមានសេរីភាព ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនាពេលខាងមុខ។

## ៤.៤ ការបកស្រាយវិធាន៦៨(៣)

៤៣. មេធាវីការពាររបស់ ខៀវ សំផន បានលើកឡើងថា វិធាន៦៨(៣) និងមាត្រា៣០៥ និងមាត្រា២៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានកំហិតយ៉ាងដាច់ខាតឲ្យបន្តការឃុំខ្លួនបណ្តោះអាសន្នចំនួនតែបួនខែ បន្ទាប់ពី ស.ច.ស ចេញដីកាដំណោះស្រាយ លើកលែងតែជនជាប់ចោទត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលនេះ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការបកស្រាយបែបនេះគឺជាការបកស្រាយដោយការភាន់ច្រឡំលើវិធាន៦៨(៣)។ ការយោងទៅរកបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគឺមិនមានលក្ខណៈចាំបាច់នោះទេ ដោយហេតុថាវិធាន៦៨(៣) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបន្តចិរវេលារហូតដល់រយៈពេលបួនខែក្រោយពីមាន "សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬរក្សាលក្ខខណ្ឌនៃការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ" (គូសបញ្ជាក់បន្ថែម)។ រយៈពេលបួនខែនៃការបន្តការឃុំខ្លួនបណ្តោះអាសន្ន បានចាប់ផ្តើមគិតពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ ជាកាលបរិច្ឆេទដែលអង្គជំនុំជម្រះសាលាដំបូងបានទទួល

[៦២] "ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន", C20/8, ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

ការជូនដំណឹងអំពីសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងជាថ្ងៃដែលអង្គជំនុំជម្រះទទួលសំណុំរឿងជាផ្លូវការ។ កាលបរិច្ឆេទនេះមិនទាន់ផុតរលត់នៅឡើយទេនៅពេលដែល ខៀវ សំផន ត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំ ជម្រះនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១១ ដោយអនុលោមតាមវិធាន ៨២(១)។

**តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង**

**សម្រេចថា** អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ដោយមានសុពលភាពត្រឹមត្រូវ។

**សម្រេចថា** ការយឺតយ៉ាវក្នុងការចេញសំអាងហេតុលើផ្នែកពាក់ព័ន្ធនឹងការឃុំខ្លួនក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ គឺជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ។

**ប្រកាសថា** លក្ខណៈនៃសំណងដែលជាបច្ច័យមកពីការរំលោភលើសិទ្ធិនេះនឹងត្រូវដោះស្រាយនៅដំណាក់កាលចុងក្រោយនៃការជំនុំជម្រះក្តីបន្ទាប់ពីបានស្តាប់ទឡ្ហីករណ៍របស់ភាគីនីមួយៗលើបញ្ហានេះ។

**សម្រេចបដិសេធ** សំណើសុំដោះលែងឱ្យនៅក្រៅឃុំរបស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ។

**កត់សម្គាល់ថា** នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ត្រូវបាននាំមកបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំ-ជម្រះ តាមវិធាន៨២(១) រួចហើយ ហើយជនជាប់ចោទទាំងបីរូបត្រូវតែស្ថិតនៅក្នុងមន្ទីរឃុំឃាំងបន្តទៀតរហូតអង្គជំនុំជម្រះចេញសាលក្រម លើកលែងតែមានការដាក់សំណើសុំឱ្យដោះលែងអនុលោមតាមវិធាន៨២។

ភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C B T C